# មេរៀនទី៧២៖ ព្រះយេស៊ូវលេចមកឯសិស្សរបស់ទ្រង់

## យ៉ូហាន ២០៖ ១៩- ៣១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/6mxcOdGyo5k

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/-k0IB1ZorIA

**គោលបំណង៖** ជឿថាព្រះយេស៊ូវមានជន្មរស់ឡើងវិញ។

**ខគម្ពីរចងចាំ៖ យ៉ូហាន ២០៖២៩** *“ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ថូម៉ាសអើយអ្នកជឿ ដោយព្រោះបានឃើញខ្ញុំទេតើ មានពរហើយ អ្នកណាដែលជឿឥតឃើញសោះ”*។

**ចំរៀង** ( *យូធូបលីង* )៖

១. ទ្រង់ជាព្រះ https://youtu.be/JWTOzAqGcyI

២. ទ្រង់រស់សព្វថ្ងៃ https://youtu.be/Ux9ClfRcNSw

៣.មានព្រះគ្រីស្ទគង់ក្នុងទូក https://youtu.be/2eORYd5n2l8

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ខ្ញុំជានរណា ?»

សម្ភារៈដែលត្រូវការ៖ ក្រមា

១. ឲ្យកុមារអង្គុយជារង្វង់នៅក្នុងថ្នាក់

២. រើសកុមារម្នាក់ធ្វើជាអ្នកចាំទី ឲ្យគាត់នៅចំកណ្តាល ហើយចងភ្នែកគាត់

៣. បង្វិលកុមារដែលត្រូវគេរុំភ្នែកនោះ ឲ្យបាន៣ជុំ ហើយឲ្យគាត់ដើរទៅប៉ះកុមារណាដែលអង្គុយក្នុងរង្វង់ដោយចាប់ដៃកុមារនោះ

៤. នៅពេលដែលកុមារដែលត្រូវគេរុំភ្នែកនោះ ចាប់ដៃកុមារណាម្នាក់បាន កុមារនោះត្រូវធ្វើសម្លេងសត្វ ហើយកុមារដែលត្រូវកគេរុំភ្នែកនោះ ត្រូវទាយឈ្មោះកុមារនោះ ( តាមរយៈការការស្តាប់សម្លេងសត្វនោះ )។

៥. ប្រសិនបើកុមារដែលត្រូវគេរុំភ្នែកនោះ ទាយត្រូវកុមារនោះត្រូវធ្វើជាអ្នកចាំទីវិញម្តង។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពេលខ្លះយើងបានឮពីព្រះបន្ទូលរបស់ព្រះ ប៉ុន្តែយើងនៅតែមានការសង្ស័យ។ យើងត្រូវតែរឹកហាត់ត្រចៀកខាងឯប្រលឹងវិញ្ញាណរបស់យើង ដើម្បីឲ្យយើងអាចឮបាននៅពេលដែលទ្រង់មានព្រះបន្ទូលមកកាន់យើង។

### ៤. ការណែនាំមេរៀន

តើប្អូនជឿលើឪពុកម្តាយរបស់ប្អូនដែរឬទេ ? តើប្អូនមានមិត្តភក្តិដែលប្អូនអាចទុកចិត្តបានដែរឬទេ ? បន្ទាប់ពីព្រះស៊ូវបានសុគត នៅលើឆ្កាង ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ។ មានមនុស្សមួយចំនួនមិនអាចជឿថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញទេ។ ថ្ងៃនេះយើងនឹងរៀនពីមនុស្សដែលបានមកជឿថា ព្រះយេ-ស៊ូវ ឈ្នះលើសេចក្តីស្លាប់ ហើយបានត្រឡប់មកមានជីវិតឡើងវិញ ដើម្បីក្លាយទៅស្តេចលើអស់ទាំងស្តេច និងជាព្រះលើអស់ទាំងព្រះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅពេលបថ្ងៃអាទិត្យ ពួកសិស្សជាច្រើននាក់បានមកជួបជុំគ្នា ហើយពួកគេមានការភ័យខ្លាចជាខ្លាំង។ ថ្ងៃនោះជា ថ្ងៃទី៣ បន្ទាប់ពីព្រះយេស៊ូវបានសុគត។ ពួកសិស្សទាំងនោះខ្លាចអ្នកដឹកនាំជនជាតិយូដា ជាអ្នកដែលបានធ្វើគត់ព្រះយេស៊ូវណាស់ ដូច្នេះពួកគេបានចាក់សោរទ្វាផ្ទះ ហើយទៅលាក់ខ្លួនពីមនុស្សដទៃទៀត។

ព្រះគម្ពីរបានប្រាប់ថា ព្រះយេស៊ូវទ្រង់យាងមកឈរនៅកណ្ដាលពួកសិស្សទាំងមានព្រះបន្ទូលថា "សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខចុះ" ទ្រង់ក៏បង្ហាញព្រះហស្ត និងចំហៀងទ្រង់ឲ្យគេមើលកន្លែងដែលគេចាក់ទំលុះ។ ព្រះគម្ពីរបានប្រាប់ថា "ពួកសិស្សមានចិត្តត្រេកអរ ដោយបានឃើញព្រះអម្ចាស់។"

រីឯ ថូម៉ាសជាម្នាក់ក្នុងចំណោមពួកសិស្សទាំង ១២ គាត់មិននៅជាមួយក្នុងកាលដែលព្រះយេស៊ូវយាងមកនោះទេ ដូច្នេះពួកសិស្សឯទៀតប្រាប់គាត់ថា យើងបានឃើញព្រះអម្ចាស់ តែគាត់ឆ្លើយថា ព្រះគម្ពីរ **យ៉ូហាន ២០៖២៥** "បើ ខ្ញុំមិនឃើញ ស្នាមដែកគោល នៅព្រះហស្តទ្រង់ ទាំងលូកម្រាមទៅក្នុងស្នាមដែកគោលនោះ ហើយលូកដៃ ខ្ញុំទៅក្នុង ចំហៀងទ្រង់ នោះខ្ញុំមិនព្រមជឿទេ"។

មួយអាទិត្យក្រោយមក ពេលដែលថូម៉ាស និងពួកសិស្សបានចូលមកក្នុងផ្ទះនោះម្ដងទៀត ព្រះយេស៊ូវក៏បានលេចមកឯពួកសិស្សម្ដងទៀត! រួចទ្រង់មានព្រះបន្ទូលទៅថូម៉ាសថា ព្រះគម្ពីរ **យ៉ូហាន ២០៖២៧** "ចូរលូក ម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំឯណេះ ហើយលូកដៃមកក្នុងចំហៀងខ្ញុំផង កុំឲ្យមានចិត្តមិនជឿឡើយ ត្រូវឲ្យជឿចុះ។"

នោះថូម៉ាសក៏ជឿថា ជាព្រះយេស៊ូវ ហើយទូលឆ្លើយថា "ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ!"

**យ៉ូហាន ២០៖២៩** "ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ថូម៉ាសអើយ អ្នកជឿដោយព្រោះបានឃើញខ្ញុំទេតើ មានពរហើយ អ្នកណាដែលជឿតឥតឃើញសោះ"។ យើងបានទទួល ព្រះពរដោយសារតែយើង ជឿលើព្រះយេស៊ូវទោះបីជា យើងមិនដែលឃើញព្រះយេស៊ូវ ដូចជាពួកសិស្ស និងថូម៉ាសក៏ដោយ។

យើងជឿថាព្រះយេស៊ូវ ទ្រង់គឺជាព្រះរាជបុត្រាដែលយាងមកផែនដីដើម្បីសុគតសំរាប់អំពើបាបរបស់យើង **រ៉ូម ៦៖២៣** ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់។ ដោយសារព្រះយេស៊ូវសុគតសំរាប់យើងឥឡូវនេះ យើងអាចទទួលអំណោយរបស់ព្រះគឺជីវិតអស់កល្បជានិច្ច ដោយសារយើងជឿលើព្រះយេស៊ូវគ្រីស្ទគឺជាព្រះអម្ចាស់នៃយើង! អំណោយនេះពិតជាអស្ចារ្យណាស់។

## ៦. សំនួរពិភាក្សា

១.តើពួកសិស្សបានធ្វើអ្វី បន្ទាប់ពីព្រះយេស៊ូវសុគតលើឈើឆ្កាង? *(ពួកគេលាក់ខ្លួនពីអ្នកដឹកនាំជន ជាតិយូដាជាអ្នកដែលធ្វើគត់ព្រះយេស៊ូវ)*

២.តើព្រះយេស៊ូវចូលមកក្នុងបន្ទប់របស់ពួកសិស្សដោយរបៀបណា? *(ទ្រង់បានលេចមកឯពួកសិស្ស ទោះបីជាទ្វារបានចាក់សោរជិត)*

៣.តើថូម៉ាសបាននិយាយថា ត្រូវការឲ្យឃើញហេតុការណ៍អ្វីកើតឡើងខ្លះ មុនពេលគាត់ជឿថា ព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ? *(ថូម៉ាស់និយាយថាត្រូវការឃើញស្នាមដែកគោល នៅព្រះហស្តទ្រង់ទាំង លូកម្រាមទៅក្នុងស្នាមដែកគោលនោះ ហើយលូកដៃខ្ញុំទៅក្នុងចំហៀងទ្រង់)*

៤.តើថូម៉ាសនិយាយអ្វីខ្លះពេលដែលព្រះយេស៊ូវបានលេចមកមុខគាត់ ហើយបានបង្ហាញស្នាមដែកគោលឲ្យគាត់មើល? *(ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ!)*

៥.តើព្រះយេស៊ូវមានបន្ទូលថាអ្នកណាមានពរច្រើនជាងគេ? *(អស់អ្នកដែលជឿព្រះយេស៊ូវដែលឥតបានឃើញទ្រង់សោះ)*

**៧. ល្បែងកំសាន្ត «គូសរូបភាពព្រះយេស៊ូវ»**

សម្ភារៈដែលត្រូវការ៖ ក្រមាឬម៉ាស ក្រដាសរាម ខ្មៅដៃ ឬហ្វឺត

១. គ្រូត្រូវបិតក្រដាសនៅលើជញ្ជាំងតាមចំនួនក្រុម

២. យើងបែងចែកកុមារជា២ឬ៣ក្រុម ឲ្យកុមារឈរជាជួរ បែរមុខទៅផ្ទាំងក្រដាស ដែលបានបិទភ្ជាប់ទៅនឹងជញ្ជាំង

៣.ឲ្យខ្មៅដៃ ឬហ្វឺតទៅកុមារដំបូងនៃកុមារនីមួយៗ ហើយឲ្យពួកគេចាប់ផ្ដើមគូស សមាជិកក្រុមជាអ្នកដែលប្រាប់គេថាត្រូវគូសអ្វីខ្លះ ( ក្បាល ភ្នែក ត្រចៀក ច្រមុះ ។ល។)

៤. នៅពេលដែលកុមារបានបញ្ចប់ផ្នែករបស់គេរួច ( ក្បាល ភ្នែក ត្រចៀក ច្រមុះ ។ល។) ហើយកុមារបន្ទាប់ក៏ចាប់ផ្ដើមបិទភ្នែកហើយគូសរូបព្រះយេស៊ូវបន្ត។ សមាជិកក្រុមទាំងអស់ត្រូវប្តូរវេនគ្នាបន្តបន្ទាប់រហូតដល់គូសរូបព្រះយេស៊ូវរួច។

៥.ក្រុមណាដែលគូសរូបរបស់ព្រះយេស៊ូវបានល្អជាងគេក្រុមនោះជាអ្នកឈ្នះល្បែងនេះ។ (ឲ្យកុមារបោះឆ្នោតដោយការលើកដៃថា តើក្រុមណាដែលគូសរូបបានល្អជាងគេ)

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា សមាជិកក្រុមត្រូវស្ដាប់ក្រុមរបស់ពួកគេក្នុងការគូសរូបព្រះយេស៊ូវ។ ដូចគ្នាដែរ យើងត្រូវ តែស្ដាប់ព្រះយេស៊ូវដោយប្រុងប្រយ័ត្ននិងឲ្យបានច្បាស់លាស់។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន ២០៖២៩** *“ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ថូម៉ាសអើយអ្នកជឿ ដោយព្រោះបានឃើញខ្ញុំទេតើ មានពរហើយ អ្នកណាដែលជឿឥតឃើញសោះ”។*

**៩. ហត្ថកម្ម**

សំភារៈដែលត្រូវការ៖ ក្រដាស ខ្មៅដៃ កន្ត្រៃ និងកាវបិត



១.បត់ក្រដាស ហើយឲ្យកុមារដានដៃរបស់ពួកគេនៅលើក្រដាស។

២. កាត់រូបដាននោះ ប៉ុន្តែកាត់កុំ ឲ្យដាច់មេដៃ និងចង្អុលដៃ។

៣.បន្ទាប់មកលាក្រដាសដែលកាត់រួចនោះ ហើយប្អូននឹងអាចឃើញបេះដូង មួយ។




៤.យករូបនេះទៅបិតលើក្រដាសផ្សេងមួយទៀត។

៥.សរសេរពាក្យថា ខ្ញុំជឿលើព្រះយេស៊ូវ នៅលើបាតដៃឬនៅលើបេះដូង។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖** (**សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន**)
តើអ្នកធ្លាប់មានអារម្មណ៍ដូចជាថូម៉ាសដែរឬទេ? **យ៉ូហាន ២០៖២៩** ព្រះយេស៊ូវបានបង្ហាញខ្លួននៅចំពោះមុខថូម៉ាស ហើយទ្រង់ជួយថូម៉ាសឲ្យបានឃើញព្រះយេស៊ូវមានព្រះជន្មឡើងវិញ។ ព្រះគម្ពីរបានប្រាប់ថា ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា អ្នកជឿដោយព្រោះបានឃើញ ខ្ញុំទេតើ មានពរហើយអ្នកណាដែលជឿឥតឃើញសោះ៕ ព្រះយេស៊ូវកំពុងតែមានបន្ទូលអំពីអ្នក! វាជាជំនឿដ៏អស្ចារ្យក្នុងការជឿដែលឥតបានឃើញ ឬដែលបានប៉ះព្រះយេស៊ូវសោះ ដូច្នេះហើយបានជាព្រះអង្គបានត្រាស់ហៅអ្នកឲ្យមានទំនាក់ទំនងជាមួយនឹងទ្រង់ "សូមព្រះប្រទានពរ" ។